**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

ថ្ងៃចន្ទ ៦កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

# សេចក្តីជូនព័ត៌មាន

## ស្តីពីការហាមឃាត់ការផ្សព្វផ្សាយលក់ តេស្តរក Covid-19 គ្មានលេខបញ្ជិកា និងគ្មានការទទួលស្គាល់ពីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជូនព័ត៌មានដល់សាធារណជន និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់ឱ្យបានជ្រាបថា៖ មានគណនីចំនួន២ ១. លក់សំភារៈពេទ្យបោះដុំនៅKhmer ២.Kheang Tun កំពុងផ្សព្វផ្សាយលក់ តេស្តរក Covid-19 ដែលគ្មានលេខបញ្ជិកា និងគ្មានការទទួលស្គាល់ពីក្រសួងសុខាភិបាល។

អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថ តម្រូវឱ្យរាល់ការចរាចរឱសថ ឧបករណ៍បរិក្ខារពេទ្យ ក៏ដូចជាប្រតិករសម្រាប់ធ្វើរោគវិនិច្ឆ័យគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខបញ្ជិកា ហើយរាល់ការផ្សព្វផ្សាយផលិតផលទាំងនេះត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល។ ដើម្បីទប់ស្កាត់ការចម្លងរីករាលដាលនៃជំងឺ Covid-19 ក្រសួងសុខាភិបាលសូមជម្រាបជូនសាធារណជនថា ក្នុងករណីបងប្អូនសង្ស័យថាមានជំងឺ Covid-19 សូមទៅពិនិត្យនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលមានគ្រូពេទ្យអាចកំណត់បានពីករណីសង្ស័យពិតប្រាកដ និងមានវិធីសាស្ត្រក្នុងការស្រង់យកវត្ថុវិភាគ។ ចំពោះវត្ថុវិភាគទាំងអស់ត្រូវបញ្ជូនទៅ ធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដែលជាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ទទួលស្គាល់ដោយក្រសួងសុខាភិបាល។

ក្រសួងសុខាភិបាល សូមជូនព័ត៌មានដល់បងប្អូនប្រជាពលរដ្ឋ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មិនត្រូវប្រើប្រាស់តេស្តរក Covid-19 គ្មានលេខបញ្ជិកា ដែលបានផ្សព្វផ្សាយលក់តាមគណនីទាំង២ ១. លក់សំភារៈ ពេទ្យបោះដុំនៅKhmer ២.Kheang Tun និងតាមប្រភពផ្សេងៗជាបន្តទៀត ព្រោះតេស្តរហ័សទាំងនេះ មិនអាចធានាបាននូវគុណភាពស្របតាមបទដ្ឋានកំណត់ឡើយ។ ក្រសួងសុខាភិបាលនឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ដែលមានជាធរមាន ចំពោះម្ចាស់គណនីហ្វេសប៊ុកខាងលើ និងជននិកាសនិយមផ្សេងៗទៀតដែលនៅតែបន្តលក់តេស្តរកCovid-19 គ្មានលេខបញ្ជិកា និងគ្មានការការទទួលស្គាល់ពីក្រសួងសុខាភិបាល។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋបានជួបប្រទះឃើញជនណាកំពុងលក់ តេស្តរក Covid-19 គ្មានលេខបញ្ជិកា សូមបងប្អូនប្រញាប់ផ្តល់ព័ត៌មានឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬត្រូវការព័ត៌មានបន្ថែមពីក្រសួងសុខាភិបាល សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ៖០១១ ៨៧៤ ៧៨៧, ០១២ ៩៨៣ ៣៣៦។

សូមភ្ជាប់មកជាមួយនូវរូបភាពគណនីទាំង ២ ខាងលើ និងតេស្តរក Covid-19 គ្មានលេខបញ្ជិកា។

ទំព័រទី ១/៣

# រូបភាពឈ្មោះគណនី និងតេស្តរក Covid-19 គ្មានលេខបញ្ជិកា



**Kheang Tun** added 5 new photos.

11 hrs •

👍ឧបករណ៍ពិនិត្យមើល មេរោគ COVID-19, លក់ដុំ និង រាយ Khmer Pop, 093 555 605

















ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៦ ៩០៩

# រូបភាពឈ្មោះគណនី និងតេស្តរក Covid-19 គ្មានលេខបញ្ជិកា

Home Posts Reviews Videos Photos About Groups

**លក់សំភារះពេទ្យបោះដុំនៅKhmer**

March 5 at 10:08 PM ·

ប្រដាប់តេស្តរកCovid-19មានលក់ដំបូងគេនៅក្នុងប្រទេសកម្ពុជាយើងហើយ មានប្រទេសផ្សេងដូចជា ចិន ជប៉ុន អ៊ីតាលី...ហើយឥឡូវនេះសូម្បីតែអាមេរិចក៏បានបញ្ជាទិញ ផងដែរ នៅចាំអីទៀត បើប្រទេសផ្សេងនៅលើសាកលលោក គេប្រើប្រាស់ឧបករណ៍តេស្តនេះ ចុះហេតុអីខ្មែរមិនអាចប្រើបានដូចគេទៅ.

បើរបស់គ្មានគុណភាព កំរដ្ឋាភិបាលចិន ជប៉ុន អ៊ីតាលី អាមេរិក.. កំគេមិនអនុញ្ញាតអោយផាចរណ៍លក់ក្នុងប្រទេសគេដែរ.

#មានវិញ្ញាបនបត្របញ្ជាក់ពីរដ្ឋាភិបា... See More






ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៦ ៩០៩